ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៨១ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ការរៀបចំនិងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៨ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីស្ថិតិ
- បានឃើញអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់អំពីការគ្រប់គ្រងរាល់ការងាររៀបចំនិងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ ដើម្បីកសាងគោលនយោបាយស្ថិតិផ្លូវការក្នុងការបង្កើតនិងការដឹកនាំប្រព័ន្ធស្ថិតិជាតិរួមបញ្ចូលគ្នាមួយ។

**មាត្រា២.-**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់ស្ថិតិផ្លូវការដែលបានចាត់តាំងទាំងអស់ និងអង្គភាពស្ថិតិក្រសួង ស្ថាប័នរាជរដ្ឋាភិបាល។

**មាត្រា៣.-**

វាក្យសព្ទសំខាន់ទាំងឡាយក្នុងអនុក្រឹត្យនេះមានន័យដូចខាងក្រោមៈ

១- **មន្ត្រីស្ថិតិដែលបានចាត់តាំង** សំដៅដល់មន្ត្រីនៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ដែលត្រូវបានប្រគល់សិទ្ធិសម្រាប់អនុវត្តសកម្មភាពស្ថិតិតាមគោលបំណងនៃច្បាប់ស្តីពីស្ថិតិនិង អនុក្រឹត្យនេះ។

២- **អង្គភាពស្ថិតិដែលបានចាត់តាំង** សំដៅដល់អង្គភាពស្ថិតិកណ្តាលរបស់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ដែលបានកំណត់ដោយរាជរដ្ឋាភិបាលឱ្យទទួលខុសត្រូវក្នុងការផលិតស្ថិតិផ្លូវការដែលបានចាត់តាំង។

៣- **អគ្គនាយក** សំដៅដល់អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ។

៤- **ទម្រង់ឬកម្រងសំណួរ** សំដៅដល់ឧបករណ៍មួយសម្រាប់ប្រមូលទិន្នន័យដែលរៀបចំដោយអគ្គនាយក វិទ្យាស្ថានជាតិស្ថិតិនិងប្រធានអង្គភាពស្ថិតិដែលបានចាត់តាំងដទៃទៀត។

៥- **ទីបរិវេណ** សំដៅដល់ទីកន្លែងដែលមិនមែនជាលំនៅឋាន ឬជាផ្នែកមួយនៃទីណាមួយក្នុងបរិវេណ ដែលត្រូវបានកាន់កាប់ដោយឡែក ឬប្រើប្រាស់សម្រាប់គោលបំណងនៃការរស់នៅ ឬស្នាក់នៅរបស់ មនុស្ស។

៦- **កាតព្វកិច្ចស្ថិតិ** សំដៅដល់ភារកិច្ចដែលអ្នកឆ្លើយទាំងឡាយត្រូវផ្តល់ព័ត៌មានស្មោះត្រង់ ត្រឹមត្រូវ គ្រប់គ្រាន់ និងទាន់ពេលវេលាតាមគ្រប់សំណួរនៃការប្រមូលទិន្នន័យស្ថិតិ។

## ជំពូកទី២
## ការរៀបចំនិងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ

**មាត្រា៤.-**

ប្រព័ន្ធស្ថិតិជាតិត្រូវបានបង្កើតឡើងជាប្រព័ន្ធស្ថិតិផ្លូវការរបស់រាជរដ្ឋាភិបាល។

ប្រព័ន្ធស្ថិតិជាតិមានវិទ្យាស្ថានជាតិស្ថិតិ មានអង្គភាពស្ថិតិដែលបានចាត់តាំងដទៃទៀត និងមន្ត្រីដែល បម្រើការងារនៅតាមអង្គភាពស្ថិតិទាំងនោះ។

អង្គភាពស្ថិតិនីមួយៗត្រូវដឹកនាំដោយប្រធានមួយរូបនិងអនុប្រធានមួយចំនួនតាមការជាក់ស្តែង។

ប្រព័ន្ធស្ថិតិជាតិត្រូវដឹកនាំដោយអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិដែលជាប្រធានមន្ត្រីស្ថិតិនៃព្រះរាជាណាចក្រ កម្ពុជា។

**មាត្រា៥.-**

វិទ្យាស្ថានជាតិស្ថិតិជាស្ថាប័នសម្រាប់ធ្វើគោលនយោបាយស្ថិតិផ្លូវការរបស់រាជរដ្ឋាភិបាលក្នុងការបង្កើត និងដឹកនាំប្រព័ន្ធស្ថិតិជាតិរួមបញ្ចូលគ្នាមួយដែលគ្របដណ្តប់ស្ថិតិផ្លូវការដែលបានចាត់តាំងទាំងអស់របស់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល។

វិទ្យាស្ថានជាតិស្ថិតិមាននាយកដ្ឋានមួយចំនួនសម្រាប់ទទួលខុសត្រូវលើសកម្មភាពស្ថិតិជំនាញនិងការគាំទ្រសកម្មភាពទាំងនោះ។

**មាត្រា៦ .-**

វិទ្យាស្ថានជាតិស្ថិតិជាស្ថាប័នស្ថិតិជាតិផ្លូវការរបស់រាជរដ្ឋាភិបាលមានភារកិច្ចទទួលខុសត្រូវដូចតទៅ៖

ក- ប្រមូល កែច្នៃ ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយស្ថិតិផ្លូវការនិងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិ។

ខ- ស្រាវជ្រាវ ចងក្រងវិធីសាស្ត្រផ្សេងៗ អភិវឌ្ឍម៉ូដែល និងបច្ចេកទេសស្ថិតិ ដើម្បីបង្កើនគុណភាពស្ថិតិផ្លូវការ។

គ- ធានាការសម្របសម្រួលប្រតិបត្តិការរបស់អង្គភាពស្ថិតិដែលបានចាត់តាំងក្នុងការប្រមូល កែច្នៃ ចងក្រង វិភាគ បោះពុម្ព ផ្សព្វផ្សាយស្ថិតិផ្លូវការនិងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិ ដើម្បី៖

- ចៀសវាងនូវការជាន់ភារកិច្ចគ្នាក្នុងការប្រមូលព័ត៌មានសម្រាប់គោលបំណងស្ថិតិផ្លូវការ ដោយអង្គភាពស្ថិតិដែលបានចាត់តាំង
- ទទួលបាននូវភាពត្រូវគ្នានិងរួមបញ្ចូលគ្នារវាងស្ថិតិផ្លូវការទាំងឡាយដែលចងក្រងដោយអង្គភាពស្ថិតិដែលបានចាត់តាំង
- ធ្វើឱ្យមានប្រសិទ្ធភាពដល់កិច្ចអភិវឌ្ឍ ការរៀបចំជាឯកសារ និងការផ្សព្វផ្សាយអំពីទស្សនៈប្រភពនិងវិធីសាស្ត្រស្ថិតិ
- អនុវត្តគោលនយោបាយស្ថិតិដែលមានរួមបញ្ចូលនូវគោលនយោបាយទាក់ទងនឹងការផ្សព្វផ្សាយស្ថិតិផ្លូវការនិងប្រតិទិនប្រកាសផ្សាយជាមុននូវការផ្សព្វផ្សាយស្ថិតិផ្លូវការ
- បង្កើនលទ្ធភាពប្រើប្រាស់ជាអតិបរមានូវព័ត៌មាននិងមធ្យោបាយនៃការប្រមូល និងផ្សព្វផ្សាយព័ត៌មានដែលមាននៅតាមអង្គភាពស្ថិតិដែលបានចាត់តាំង។

ឃ- រៀបចំគោលនយោបាយនិងបទដ្ឋានស្ថិតិសម្រាប់ការអនុវត្តឯកភាពគ្នារបស់អង្គភាពស្ថិតិដែលបានចាត់តាំង។

ង- ផ្តល់ការណែនាំនិងជួយគាំទ្រដល់អង្គភាពស្ថិតិដែលបានចាត់តាំងទាក់ទងនឹងស្ថិតិផ្លូវការ។

ច- ទំនាក់ទំនងជាមួយបណ្តាប្រទេសនានានិងអង្គការអន្តរជាតិនានាដែលទាក់ទងនឹងការងារស្ថិតិ។

វិទ្យាស្ថានជាតិស្ថិតិត្រូវសហការជាមួយអង្គភាពស្ថិតិផ្លូវការដែលបានចាត់តាំងរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ក្នុងការប្រមូល ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយស្ថិតិរួមទាំងស្ថិតិដែលទទួលបានពីកំណត់ត្រារដ្ឋបាល ក្នុងគោលបំណងសម្របសម្រួលសកម្មភាពស្ថិតិនិងធានាការប្រតិបត្តិបទដ្ឋានស្ថិតិ។

**មាត្រា៧ .-**

អគ្គនាយកត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។ អគ្គនាយកត្រូវបំពេញតួនាទីភារកិច្ចតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីស្ថិតិនិងអនុក្រឹត្យនេះ ហើយមិនត្រូវបំពេញការងារផ្សេងលើកលែងតែមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងផែនការ។

អគ្គនាយកត្រូវដឹកនាំវិទ្យាស្ថានជាតិស្ថិតិនិងប្រព័ន្ធស្ថិតិជាតិ និងជាប្រធានមន្ត្រីស្ថិតិនៃព្រះរាជាណាចក្រកម្ពុជា។

អគ្គនាយកត្រូវដឹកនាំ ត្រួតពិនិត្យការរៀបចំ និងកិច្ចដំណើរការរបស់វិទ្យាស្ថានជាតិស្ថិតិ ប្រព័ន្ធស្ថិតិជាតិ ហើយនិងមានមុខងារ សិទ្ធិអំណាច និងភារកិច្ចដទៃទៀតៈ

ក- ផ្តល់យោបល់អំពីការងារស្ថិតិ។

ខ- សម្រេចអំពីរបៀបប្រមូល កែច្នៃ ចងក្រង វិភាគ និងផ្សព្វផ្សាយទិន្នន័យទាំងឡាយសម្រាប់គោលដៅស្ថិតិ។

គ- ផ្តល់ព័ត៌មានទាក់ទងនឹងបទប្បញ្ញត្តិ គោលនយោបាយស្ថិតិ ស្ថិតិផ្លូវការ និងការងារស្ថិតិដទៃទៀត។

ឃ- តំណាងឱ្យប្រព័ន្ធស្ថិតិជាតិក្នុងវេទិកាអន្តរជាតិដែលទាក់ទងទៅនឹងការងារស្ថិតិ។

**មាត្រា៨.-**

អគ្គនាយកអាចចុះហត្ថលេខាធ្វើប្រតិភូកម្មដល់មន្ត្រីណាម្នាក់នូវសិទ្ធិអំណាចសម្រាប់ចុះបំពេញការងារប្រមូលទិន្នន័យឬសម្របសម្រួលដើម្បីប្រមូលទិន្នន័យ ដូចមានចែងក្នុងច្បាប់ស្តីពីស្ថិតិនិងអនុក្រឹត្យនេះ។

សិទ្ធិអំណាចរបស់មន្ត្រីដែលត្រូវបានទទួលប្រតិភូកម្មនៅពេលអនុវត្តតាមច្បាប់ស្តីពីស្ថិតិនិងអនុក្រឹត្យនេះ ត្រូវបានចាត់ទុកថាអនុវត្តដោយអគ្គនាយក។

**មាត្រា៩.-**

អគ្គនាយកត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំដែលទាក់ទងនឹងសកម្មភាពនៃកិច្ចប្រតិបត្តិការស្ថិតិហើយនិងការផ្សព្វផ្សាយ និងការប្រើប្រាស់ស្ថិតិផ្លូវការរបស់ប្រព័ន្ធស្ថិតិជាតិសម្រាប់ឆ្នាំកន្លងមក ហើយផ្ញើជូនរដ្ឋមន្ត្រីក្រសួងផែនការ។

រដ្ឋមន្ត្រីក្រសួងផែនការត្រូវផ្ញើរបាយការណ៍ប្រចាំឆ្នាំជូនគណៈរដ្ឋមន្ត្រី។

**មាត្រា១០.-**

ប្រធានអង្គភាពស្ថិតិដែលបានចាត់តាំងត្រូវសម្របសម្រួលជាមួយអគ្គនាយក ក្នុងករណីធ្វើអង្កេត ប្រមូល ចងក្រងទិន្នន័យតាមវិស័យរបស់ខ្លួន ដោយសហការជាមួយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងត្រូវផ្ញើឈ្មោះមន្ត្រីដែលត្រូវចូលរួមមកក្រសួងផែនការ ដើម្បីចាត់តាំងរួមជាមួយមន្ត្រីក្រសួងផែនការ ចុះប្រតិបត្តិការអង្កេត។

**មាត្រា១១.-**

មន្ត្រីរបស់វិទ្យាស្ថានជាតិស្ថិតិ រួមមាន បុគ្គលិកអចិន្ត្រៃយ៍ដែលជាមន្ត្រីរបស់វិទ្យាស្ថានជាតិស្ថិតិ ហើយបំពេញមុខងារដូចមានចែងក្នុងមាត្រា១២និងមាត្រា២៣នៃច្បាប់ស្តីពីស្ថិតិ។

អគ្គនាយកអាចប្រើប្រាស់បុគ្គលិកបន្ថែមដែលមិនមែនជាបុគ្គលិកអចិន្ត្រៃយ៍នៅពេលៈ

ក- ធ្វើជំរឿននិងអង្កេត។

ខ- ប្រមូលស្ថិតិផ្សេងៗនិងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិ។

គ- ផ្តល់នូវប្រឹក្សាបច្ចេកទេសនិងការគាំទ្រ។

កិច្ចសន្យាអំពីរយៈពេលនិងលក្ខខណ្ឌនៃការងាររបស់បុគ្គលិកមិនមែនអចិន្ត្រៃយ៍ត្រូវកំណត់ដោយអគ្គនាយក។

**មាត្រា១២.-**

អង្គភាពស្ថិតិដែលបានចាត់តាំងជាអង្គភាពស្ថិតិកណ្ដាលរបស់ក្រសួងឬស្ថាប័នរាជរដ្ឋាភិបាលមានភារកិច្ចទទួលខុសត្រូវដូចតទៅ៖

ក- ប្រមូល កែច្នៃ ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយស្ថិតិផ្លូវការនិងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិ។

ខ- បញ្ជូនស្ថិតិដែលបានផលិតនិងផ្ដល់ឯកសារវិធីសាស្ត្រដែលទាក់ទងដល់វិទ្យាស្ថានជាតិស្ថិតិជាទម្រង់អេឡិចត្រូនិកនិងឯកសារជាក្រដាស។

គ- សហប្រតិបត្តិការជាមួយវិទ្យាស្ថានជាតិស្ថិតិ ក្នុងការប្រមូល កែច្នៃ ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយស្ថិតិផ្លូវការនិងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិ ដើម្បី៖

- ចៀសវាងនូវការជាន់គ្នាក្នុងសកម្មភាពស្ថិតិនិងស្ថិតិផ្លូវការ
- បន្ថយមកត្រឹមកម្រិតអប្បបរមានូវបន្ទុកអ្នកឆ្លើយ
- ទទួលបាននូវការឯកភាពគ្នានិងការរួមបញ្ចូលគ្នារវាងស្ថិតិផ្លូវការទាំងឡាយ
- អនុវត្តគោលនយោបាយនិងបទដ្ឋានស្ថិតិដែលប្រកាសឱ្យប្រើដោយវិទ្យាស្ថានជាតិស្ថិតិ។

**មាត្រា១៣.-**

មន្ត្រីរបស់អង្គភាពស្ថិតិដែលបានចាត់តាំងមានបុគ្គលិកអចិន្ត្រៃយ៍ដែលជាមន្ត្រីរបស់អង្គភាពនោះ ហើយបំពេញមុខងារដែលមានចែងក្នុងមាត្រា១៣និង២៣(ក)នៃច្បាប់ស្ដីពីស្ថិតិ។

អង្គភាពស្ថិតិដែលបានចាត់តាំងអាចប្រើប្រាស់បុគ្គលិកបន្ថែម ដោយពិគ្រោះយោបល់អំពីតម្រូវការកម្រិតសមត្ថភាពរបស់បុគ្គលិកមិនមែនអចិន្ត្រៃយ៍ជាមួយអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ នៅពេល៖

ក- ធ្វើអង្កេត។

ខ- ប្រមូលស្ថិតិផ្សេងៗនិងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិ។

គ- ផ្ដល់នូវប្រឹក្សាបច្ចេកទេសនិងការគាំទ្រ។

កិច្ចសន្យាអំពីរយៈពេលនិងលក្ខខណ្ឌនៃការងាររបស់បុគ្គលិកមិនមែនអចិន្ត្រៃយ៍ត្រូវកំណត់ដោយក្រសួងឬស្ថាប័ន ដោយពិគ្រោះយោបល់ជាមួយអគ្គនាយក។

**មាត្រា១៤.-**

ទិន្នន័យបុគ្គលដែលប្រមូលដោយអង្គភាពស្ថិតិនៃប្រព័ន្ធស្ថិតិជាតិនិងទិន្នន័យផ្ទុំដែលកែច្នៃពីទិន្នន័យបុគ្គលត្រូវផ្ញើជូនវិទ្យាស្ថានជាតិស្ថិតិនៅពេលមានសំណើ។

វិទ្យាស្ថានជាតិស្ថិតិត្រូវទទួលបាននូវរាល់ទិន្នន័យរដ្ឋបាលដែលផលិតដោយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល បន្ទាប់ពីការឯកភាពរបស់ក្រុមប្រឹក្សាស្ថិតិ។ អង្គភាពស្ថិតិនៃក្រសួង ស្ថាប័នរាជរដ្ឋាភិបាលត្រូវទទួលបានរាល់ទិន្នន័យរដ្ឋបាលដែលផលិតឬគ្រប់គ្រងដោយអង្គភាពក្រោមឱវាទរបស់ក្រសួង ស្ថាប័នរបស់ខ្លួន។

## ជំពូកទី៣
## ក្រុមប្រឹក្សាស្ថិតិ

**មាត្រា១៥.-**

ក្រុមប្រឹក្សាស្ថិតិដែលបានបង្កើតដោយអនុលោមតាមមាត្រា១៦នៃច្បាប់ស្តីពីស្ថិតិមានសមាសភាពដូចតទៅ៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងផែនការ | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងផែនការ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការពារជាតិ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងបរិស្ថាន១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងព័ត៌មាន១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងទេសចរណ៍១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា១រូប | សមាជិក |

| | |
|---|---|
| - រដ្ឋលេខាធិការក្រសួងកិច្ចការនារី១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ១រូប | សមាជិក |
| - រដ្ឋលេខាធិការរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល១រូប | សមាជិក |
| - ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា១រូប | សមាជិក |
| - តំណាងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ១រូប | សមាជិក |
| - តំណាងសាកលវិទ្យាល័យឯកជន១រូប | សមាជិក |
| - តំណាងសភាពាណិជ្ជកម្មកម្ពុជា១រូប | សមាជិក |
| - តំណាងក្រុមប្រឹក្សាសហជីពជាតិកម្ពុជា១រូប | សមាជិក |
| - តំណាងសមាគមសហគ្រាសធុនតូច មធ្យម១រូប | សមាជិក |
| - តំណាងសមាគមនិយោជកកាត់ដេរកម្ពុជា១រូប | សមាជិក |
| - អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ | សមាជិកអចិន្ត្រៃយ៍។ |

សមាសភាពជាក់ស្តែងនៃក្រុមប្រឹក្សាស្ថិតិត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

ប្រធានក្រុមប្រឹក្សាស្ថិតិមានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន អ្នកឯកទេសដែលពាក់ព័ន្ធ ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនផ្សេងៗចូលរួមផ្តល់យោបល់ក្នុងករណីចាំបាច់។

**មាត្រា១៦.-**

ក្រុមប្រឹក្សាស្ថិតិត្រូវប្រជុំការងារយ៉ាងតិចពីរដងក្នុងមួយឆ្នាំ។ សមាជិកក្រុមប្រឹក្សាស្ថិតិត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

រាល់ការប្រជុំរបស់ក្រុមប្រឹក្សាស្ថិតិត្រូវកំណត់ចំនួនសមាជិកយ៉ាងតិចពាក់កណ្តាលនៃសមាជិកទាំងអស់សម្រាប់បើកអង្គប្រជុំ។ ក្នុងករណីសមាជិកចូលរួមមិនគ្រប់ កិច្ចប្រជុំលើកទី២ត្រូវមានសមាជិកចូលរួមយ៉ាងតិចមួយភាគបីនៃសមាជិកទាំងអស់។

សេចក្តីសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាស្ថិតិត្រូវអនុម័តដោយយកមតិភាគច្រើនរបស់សមាជិកចូលរួមទាំងអស់។

រដ្ឋមន្ត្រីក្រសួងផែនការដែលជាប្រធានក្រុមប្រឹក្សាស្ថិតិមានសិទ្ធិអនុម័តសម្រេចក្នុងករណីដែលមានមតិស្មើគ្នា។

រាល់ការប្រជុំរបស់ក្រុមប្រឹក្សាស្ថិតិត្រូវមានកំណត់ហេតុ។

**មាត្រា១៧.-**

ក្រុមប្រឹក្សាស្ថិតិមានសិទ្ធិប្រើប្រាស់ត្រាក្រសួងផែនការ។ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការត្រូវផ្តល់លេខាធិការដ្ឋានជូនក្រុមប្រឹក្សាស្ថិតិ។

**មាត្រា១៨.-**

ក្រុមប្រឹក្សាស្ថិតិមានតួនាទីផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងផែនការដែលទាក់ទងទៅនឹង៖

- យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ
- ការធ្វើវិសោធនកម្មណាមួយទៅលើច្បាប់ស្តីពីស្ថិតិ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធការងារស្ថិតិ
- ការកំណត់គោលនយោបាយស្ថិតិផ្លូវការ
- តម្រូវការស្ថិតិផ្លូវការនិងការផ្តល់អាទិភាពដល់គម្រោងការងារស្ថិតិ ដែលស្នើឡើងដោយវិទ្យាស្ថានជាតិស្ថិតិនិងអង្គភាពស្ថិតិដែលបានចាត់តាំង
- ការធ្វើឱ្យប្រសើរឡើង ការពង្រីក និងការសម្របសម្រួលនូវប្រព័ន្ធស្ថិតិជាតិនិងស្ថិតិផ្លូវការដែលបានចាត់តាំងសម្រាប់គោលបំណងសាធារណៈ
- កម្មវិធីការងារស្ថិតិអាទិភាពរយៈពេល១ឆ្នាំ រយៈពេលមធ្យម រយៈពេលវែងរបស់វិទ្យាស្ថានជាតិស្ថិតិនិងអង្គភាពស្ថិតិដែលបានចាត់តាំងដែលទាក់ទងក្នុងការផលិតស្ថិតិផ្លូវការ
- ការកំណត់កាលបរិច្ឆេទនៃការធ្វើជំរឿនប្រជាជន ជំរឿនកសិកម្ម និងជំរឿនសេដ្ឋកិច្ច
- ការងារផ្សេងៗដែលទាក់ទងជាទូទៅនឹងប្រព័ន្ធស្ថិតិជាតិនិងស្ថិតិផ្លូវការ
- ការស្វែងរកជំនួយនិងការគាំទ្រធនធានហិរញ្ញវត្ថុនិងធនធានមនុស្សដែលត្រូវការ ដោយវិទ្យាស្ថានជាតិស្ថិតិនិងអង្គភាពស្ថិតិដែលបានចាត់តាំង ដើម្បីធ្វើជំរឿន អង្កេត ផលិត និងផ្សព្វផ្សាយស្ថិតិផ្លូវការ សម្រាប់គោលបំណងសាធារណៈ។

## ជំពូកទី៤
## គណៈកម្មាធិការសម្របសម្រួលស្ថិតិ

**មាត្រា១៩.-**

គណៈកម្មាធិការសម្របសម្រួលស្ថិតិ ដោយអនុលោមតាមមាត្រា១៧នៃច្បាប់ស្តីពីស្ថិតិ មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ | ប្រធាន |
| - អគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ | អនុប្រធាន |
| - ប្រធានអង្គភាពស្ថិតិទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - ប្រធានអង្គភាពស្ថិតិក្រសួងមហាផ្ទៃ | សមាជិក |
| - ប្រធានអង្គភាពស្ថិតិក្រសួងការពារជាតិ | សមាជិក |
| - ប្រធានអង្គភាពស្ថិតិក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| - ប្រធានអង្គភាពស្ថិតិក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| - ប្រធានអង្គភាពស្ថិតិក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |

- ប្រធានអង្គភាពស្ថិតិក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក
- ប្រធានអង្គភាពស្ថិតិក្រសួងពាណិជ្ជកម្ម សមាជិក
- ប្រធានអង្គភាពស្ថិតិក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សមាជិក
- ប្រធានអង្គភាពស្ថិតិក្រសួងរ៉ែនិងថាមពល សមាជិក
- ប្រធានអង្គភាពស្ថិតិក្រសួងអប់រំ យុវជន និងកីឡា សមាជិក
- ប្រធានអង្គភាពស្ថិតិក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក
- ប្រធានអង្គភាពស្ថិតិក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
- ប្រធានអង្គភាពស្ថិតិក្រសួងបរិស្ថាន សមាជិក
- ប្រធានអង្គភាពស្ថិតិក្រសួងធនធានទឹកនិងឧតុនិយម សមាជិក
- ប្រធានអង្គភាពស្ថិតិក្រសួងព័ត៌មាន សមាជិក
- ប្រធានអង្គភាពស្ថិតិក្រសួងយុត្តិធម៌ សមាជិក
- ប្រធានអង្គភាពស្ថិតិក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច សមាជិក
- ប្រធានអង្គភាពស្ថិតិក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក
- ប្រធានអង្គភាពស្ថិតិក្រសួងសុខាភិបាល សមាជិក
- ប្រធានអង្គភាពស្ថិតិក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិក
- ប្រធានអង្គភាពស្ថិតិក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក
- ប្រធានអង្គភាពស្ថិតិក្រសួងទេសចរណ៍ សមាជិក
- ប្រធានអង្គភាពស្ថិតិក្រសួងធម្មការនិងសាសនា សមាជិក
- ប្រធានអង្គភាពស្ថិតិក្រសួងកិច្ចការនារី សមាជិក
- ប្រធានអង្គភាពស្ថិតិក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- ប្រធានអង្គភាពស្ថិតិក្រសួងមុខងារសាធារណៈ សមាជិក
- ប្រធានអង្គភាពស្ថិតិរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក
- ប្រធានអង្គភាពស្ថិតិធនាគារជាតិនៃកម្ពុជា សមាជិក
- ប្រធានអង្គភាពស្ថិតិក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
- ប្រធានអង្គភាពស្ថិតិអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមាជិក
- ប្រធានអង្គភាពស្ថិតិអគ្គនាយកដ្ឋានពន្ធដារ សមាជិក
- ប្រធានអង្គភាពស្ថិតិទីភ្នាក់ងារជាតិមុខរបរនិងការងារ សមាជិក
- ប្រធាននាយកដ្ឋានគោលនយោបាយនិងសហប្រតិបត្តិការស្ថិតិនៃវិទ្យាស្ថានជាតិស្ថិតិ លេខាធិការ។

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការសម្របសម្រួលស្ថិតិត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាស្ថិតិ។

**មាត្រា២០.-**

គណៈកម្មាធិការសម្របសម្រួលស្ថិតិត្រូវប្រជុំការងារយ៉ាងតិចរាល់៣(បី)ខែម្តង។ សមាជិកគណៈកម្មាធិការសម្របសម្រួលស្ថិតិត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

រាល់ការប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលស្ថិតិត្រូវកំណត់ចំនួនសមាជិកយ៉ាងតិចពាក់កណ្តាលនៃសមាជិកទាំងអស់សម្រាប់បើកអង្គប្រជុំ។ ក្នុងករណីសមាជិកចូលរួមមិនគ្រប់ កិច្ចប្រជុំលើកទី២មិនគិតសមាជិកចូលរួមឡើយ។

សេចក្តីសម្រេចរបស់អង្គប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិត្រូវអនុម័តដោយយកមតិភាគច្រើនរបស់សមាជិកចូលរួមទាំងអស់។

អគ្គនាយកដែលជាប្រធានគណៈកម្មាធិការសម្របសម្រួលស្ថិតិមានសិទ្ធិអនុម័តសម្រេចក្នុងករណីដែលមានមតិស្មើគ្នា។

រាល់ការប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលស្ថិតិត្រូវមានកំណត់ហេតុ។

**មាត្រា២១.-**

គណៈកម្មាធិការសម្របសម្រួលស្ថិតិមានសិទ្ធិប្រើប្រាស់ត្រាវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។

នាយកដ្ឋានគោលនយោបាយនិងសហប្រតិបត្តិការស្ថិតិនៃវិទ្យាស្ថានជាតិស្ថិតិជាលេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលស្ថិតិ។

**មាត្រា២២.-**

គណៈកម្មាធិការសម្របសម្រួលស្ថិតិមានភារកិច្ចជួយវិទ្យាស្ថានជាតិស្ថិតិក្នុងការងារពាក់ព័ន្ធទៅនឹង៖

- ការរៀបចំនិងធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ
- ការកសាងគោលនយោបាយស្ថិតិ នីតិវិធី និងបទប្បញ្ញត្តិដែលទាក់ទងនឹងប្រព័ន្ធស្ថិតិជាតិនិងស្ថិតិផ្លូវការ
- ការធ្វើសមាហរណកម្មប្រព័ន្ធស្ថិតិជាតិមួយ តាមរយៈការសម្របសម្រួលនិងសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពលើសកម្មភាពនិងការអភិវឌ្ឍស្ថិតិរវាងអង្គភាពស្ថិតិដែលបានចាត់តាំង រួមទាំងវិទ្យាស្ថានជាតិស្ថិតិ ដើម្បីទទួលខុសត្រូវក្នុងការផលិតនិងការផ្សព្វផ្សាយស្ថិតិផ្លូវការ
- ការធ្វើឱ្យប្រសើរឡើង និងការពង្រីកប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការ ដែលផ្តល់សម្រាប់គោលដៅសាធារណៈ
- ការលើកអាទិភាពនៃកម្មវិធីការងារប្រចាំឆ្នាំ រយៈពេលមធ្យម និងរយៈពេលវែងដែលគួរត្រូវបានជ្រើសរើសទាក់ទងនឹងទិដ្ឋភាពសំខាន់ៗនៃការផ្តល់ស្ថិតិផ្លូវការដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង
- ការរៀបចំផែនការធ្វើជំរឿនប្រជាជន ជំរឿនកសិកម្ម និងជំរឿនសេដ្ឋកិច្ច
- ការបង្កើតនូវបញ្ជីពាណិជ្ជកម្មឬក្របខ័ណ្ឌសរុប បញ្ជីឈ្មោះប្រភពទិន្នន័យរដ្ឋបាល និងស្ថិតិដែលទាក់ទងនឹងប្រព័ន្ធស្ថិតិជាតិ ព្រមទាំងថែរក្សាដោយប្រសិទ្ធភាពនិងធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំ
- កិច្ចព្រមព្រៀងសហប្រតិបត្តិការនិងកិច្ចសម្របសម្រួលរវាងបណ្តាក្រសួង ស្ថាប័ន និងបណ្តាអង្គភាពរាជរដ្ឋាភិបាលអំពីការផ្លាស់ប្តូរទិន្នន័យនិងការផ្តល់ទាន់ពេលវេលានូវស្ថិតិផ្លូវការឱ្យបានទៀងទាត់និងគួរជឿទុកចិត្តបាន

- ការបង្កើតក្រុមការងារបច្ចេកទេសស្ថិតិរយៈពេលកំណត់ ឬអចិន្ត្រៃយ៍សម្រាប់ស្ថិតិណាមួយ ឬការងារស្ថិតិផ្សេងទៀតដែលទាក់ទងនឹងប្រព័ន្ធស្ថិតិជាតិនិងស្ថិតិផ្លូវការ
- ការប្រកាសឱ្យប្រើនិងការអនុវត្តនូវចំណាត់ថ្នាក់និងបទដ្ឋានស្ថិតិដែលទាក់ទងនឹងស្ថិតិផ្លូវការ
- ការលើកផែនការថវិកានិងធនធានមនុស្សសម្រាប់អង្គភាពស្ថិតិដែលបានចាត់តាំង រួមទាំងវិទ្យាស្ថានជាតិស្ថិតិ ដើម្បីដឹកនាំការធ្វើជំរឿននិងអង្កេត ផលិត និងផ្សព្វផ្សាយស្ថិតិផ្លូវការសម្រាប់គោលដៅសាធារណៈ។

**មាត្រា២៣.-**

គណៈកម្មាធិការសម្របសម្រួលស្ថិតិមានសិទ្ធិបង្កើតក្រុមការងារបច្ចេកទេសស្ថិតិរយៈពេលកំណត់ឬអចិន្ត្រៃយ៍ ដើម្បីដោះស្រាយការងារបច្ចេកទេសស្ថិតិណាមួយ ដែលទាមទារការពិនិត្យ សិក្សា និងពិភាក្សាលម្អិត។

គណៈកម្មាធិការសម្របសម្រួលស្ថិតិនឹងកំណត់លក្ខខណ្ឌយោង ដែលមានចែងពីភារកិច្ចនិងបែបបទធ្វើរបាយការណ៍ស្តីពីលទ្ធផលរបស់ក្រុមការងារបច្ចេកទេសស្ថិតិនីមួយៗ។

ក្រុមការងារបច្ចេកទេសស្ថិតិនីមួយៗត្រូវរៀបចំសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - សមាជិក១រូប របស់គណៈកម្មាធិការសម្របសម្រួលស្ថិតិ | ប្រធាន |
| - ប្រធានឬអនុប្រធាននាយកដ្ឋាន១រូប នៃវិទ្យាស្ថានជាតិស្ថិតិ | អនុប្រធាន |
| - សមាជិកដទៃទៀតមកពីបណ្តាក្រសួង ស្ថាប័ន ឬអង្គភាពរាជរដ្ឋាភិបាល ដែលពាក់ព័ន្ធ រួមទាំងវិទ្យាស្ថានជាតិស្ថិតិ ដែលមានចំនួនមិនលើសពី៥រូប ទៅតាមការកំណត់របស់គណៈកម្មាធិការសម្របសម្រួលស្ថិតិ | សមាជិក។ |

## ជំពូកទី៥
## ប្រភពធនធានហិរញ្ញវត្ថុ

**មាត្រា២៤.-**

កិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិមានប្រភពធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តសកម្មភាពការងាររបស់ខ្លួន ស្របតាមមាត្រា២០ មាត្រា២១ និងមាត្រា២២នៃច្បាប់ស្តីពីស្ថិតិ។

## ជំពូកទី៦
## សិទ្ធិនិងភារកិច្ច

**មាត្រា២៥.-**

វិទ្យាស្ថានជាតិស្ថិតិ ដោយអនុលោមតាមច្បាប់ស្តីពីស្ថិតិនិងអនុក្រឹត្យដែលពាក់ព័ន្ធនឹងការងារស្ថិតិត្រូវប្រមូល៖

- ព័ត៌មានស្ថិតិជាចាំបាច់សម្រាប់គោលបំណងនៃការចងក្រងនិងការវិភាគស្ថិតិផ្លូវការដែលបានចាត់តាំង
- ព័ត៌មានស្ថិតិបន្ថែមដែលជាតម្រូវការរបស់រាជរដ្ឋាភិបាលសម្រាប់គោលដៅធ្វើផែនការនិងគោលនយោបាយ

- ព័ត៌មានស្ថិតិជាចាំបាច់សម្រាប់គោលបំណងនៃការចងក្រងនិងការវិភាគស្ថិតិផ្លូវការដែលបានចាត់តាំង
- ព័ត៌មានស្ថិតិបន្ថែមដែលជាតម្រូវការរបស់រាជរដ្ឋាភិបាលសម្រាប់គោលដៅធ្វើផែនការនិងគោលនយោបាយ
- ព័ត៌មានស្ថិតិពាក់ព័ន្ធទៅនឹងបញ្ហាដែលបានកំណត់ជាលាយលក្ខណ៍អក្សរ ដោយរដ្ឋមន្ត្រីក្រសួងផែនការឱ្យប្រមូលព័ត៌មាន។

អង្គភាពស្ថិតិដែលបានចាត់តាំង ដោយអនុលោមតាមច្បាប់ស្តីពីស្ថិតិនិងអនុក្រឹត្យនេះត្រូវប្រមូលព័ត៌មានស្ថិតិជាចាំបាច់ សម្រាប់គោលបំណងនៃការចងក្រងនិងការវិភាគស្ថិតិផ្លូវការដែលបានចាត់តាំងដែលអង្គភាពស្ថិតិនោះទទួលខុសត្រូវ។

**មាត្រា២៦.-**

អគ្គនាយកឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំងត្រូវចងក្រងនិងវិភាគព័ត៌មានស្ថិតិដែលបានប្រមូលក្រោមសិទ្ធិអំណាចនៃច្បាប់ស្តីពីស្ថិតិនិងអនុក្រឹត្យនេះ ហើយត្រូវបោះពុម្ពនិងផ្សព្វផ្សាយនូវលទ្ធផលដែលបានចងក្រងនិងវិភាគឬសម្រង់សង្ខេបនៃលទ្ធផលទាំងនោះ។ លទ្ធផលឬសម្រង់សង្ខេបនោះនឹងមិនត្រូវបានបោះពុម្ពឬផ្សព្វផ្សាយតាមរបៀបដែលអាចនាំឱ្យស្គាល់អត្តសញ្ញាណរបស់បុគ្គលឬអង្គភាពណាមួយឡើយ។

**មាត្រា២៧.-**

ក- អគ្គនាយកឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំងមានសិទ្ធិនិងកាតព្វកិច្ចដូចខាងក្រោម៖
  - រៀបចំកម្រងសំណួរឬទម្រង់ស្ថិតិទាក់ទងនឹងការប្រមូលព័ត៌មានស្ថិតិពាក់ព័ន្ធនឹងបញ្ហាជាក់លាក់ណាមួយ
  - អាចធ្វើលិខិតតម្រូវឱ្យបុគ្គលដែលមានជំនាញនិងការទទួលខុសត្រូវជាក់លាក់ ដើម្បីបំពេញកម្រងសំណួរឬទម្រង់ស្ថិតិតាមការណែនាំសម្រាប់បំពេញ។

ខ- អគ្គនាយក ឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំង ឬមន្ត្រីស្ថិតិដែលបានចាត់តាំងអាច៖
  - ឱ្យបុគ្គលបំពេញនិងផ្តល់ព័ត៌មានស្ថិតិតាមការណែនាំជាលាយលក្ខណ៍អក្សរឬដោយផ្ទាល់មាត់
  - មានវិធានការចាំបាច់ដើម្បីជំរុញឱ្យបុគ្គលបំពេញកម្រងសំណួរឬទម្រង់ស្ថិតិឱ្យបានត្រឹមត្រូវសព្វគ្រប់តាមការណែនាំ។

គ- អគ្គនាយកឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំងអាចចេញលិខិតជូនដំណឹង ដោយភ្ជាប់ជាមួយនឹងកម្រងសំណួរឬទម្រង់ស្ថិតិផ្ញើទៅបុគ្គលតាមរយៈប្រៃសណីយ៍ឬមន្ត្រីស្ថិតិជាតំណាងជូនដល់ផ្ទាល់ដៃ។ បុគ្គលដែលបានទទួលកម្រងសំណួរឬទម្រង់ស្ថិតិត្រូវបំពេញដោយទទួលខុសត្រូវនូវចម្លើយឱ្យបានសព្វគ្រប់តាមការណែនាំ ហើយផ្ញើកម្រងសំណួរឬទម្រង់ស្ថិតិដែលបានបំពេញហើយនោះ មកអគ្គនាយកឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំង ក្នុងរយៈពេលមិនឱ្យលើសពី១៤ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃដែលបានទទួលកម្រងសំណួរឬទម្រង់ស្ថិតិ។

ឃ- លិខិតជូនដំណឹងរបស់អគ្គនាយកឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំងត្រូវបញ្ជាក់អំពីទោសប្បញ្ញត្តិដែលមានចែងក្នុងមាត្រា៣៥និងមាត្រា៣៦នៃច្បាប់ស្តីពីស្ថិតិ។

**មាត្រា២៨.-**

ក- អគ្គនាយក ឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំង ឬមន្ត្រីស្ថិតិដែលបានចាត់តាំងអាចឱ្យបុគ្គលឆ្លើយនូវសំណួរណាដែលចាំបាច់ជាលាយលក្ខណ៍អក្សរឬដោយផ្ទាល់មាត់។

ខ- អគ្គនាយកឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំង ដោយលិខិតជាលាយលក្ខណ៍អក្សរ ឬដោយខ្លួនផ្ទាល់ ឬដោយចាត់មន្ត្រីស្ថិតិជាតំណាង អាចណែនាំឱ្យបុគ្គលផ្ដល់ចម្លើយនូវសំណួរណាមួយដែលចាំបាច់ក្នុងរយៈពេលមិនឱ្យលើសពី១៤ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលបានទទួលសំណួរ។

គ- សំណួររបស់អគ្គនាយកឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំងត្រូវបញ្ជាក់អំពីទោសប្បញ្ញត្តិដូចមានចែងក្នុងមាត្រា៣៥និងមាត្រា៣៦នៃច្បាប់ស្ដីពីស្ថិតិ។

**មាត្រា២៩.-**

មន្ត្រីស្ថិតិទាំងឡាយដែលត្រូវបានប្រគល់សិទ្ធិឱ្យចុះប្រតិបត្តិការការងារស្ថិតិ យោងតាមច្បាប់ស្ដីពីស្ថិតិនិងអនុក្រឹត្យពាក់ព័ន្ធ ត្រូវចុះកិច្ចសន្យាដោយមានសាក្សីទទួលដឹងឮ ដើម្បីធានា៖

- ភាពស្មោះត្រង់
- រក្សាការសម្ងាត់នូវរាល់ព័ត៌មានបុគ្គលដែលទទួលបានពីអ្នកឆ្លើយ
- ព័ត៌មានដែលប្រមូលបានត្រូវប្រើប្រាស់សម្រាប់តែគោលដៅស្ថិតិប៉ុណ្ណោះ។

**មាត្រា៣០.-**

ក្នុងករណីពិសេស រដ្ឋមន្ត្រីក្រសួងផែនការអាចសម្រេចជាលាយលក្ខណ៍អក្សរផ្ដល់ឱ្យនូវកម្រិតព័ត៌មានបុគ្គលណាមួយតាមការស្នើសុំពីអគ្គនាយកឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំងជាលាយលក្ខណ៍អក្សរ។

ការសម្រេចផ្ដល់ឱ្យអាចពាក់ព័ន្ធទៅនឹង៖

ក- បុគ្គលដែលស្នើសុំព័ត៌មាន។

ខ- តម្រូវការយល់ព្រមពីអ្នកឆ្លើយដែលបានផ្ដល់ព័ត៌មាន។

គ- ការបញ្ជាក់រយៈពេលនិងលក្ខខណ្ឌប្រើប្រាស់ព័ត៌មានដែលបានផ្ដល់ឱ្យ ដូចជា មិនបញ្ចេញព័ត៌មានដល់បុគ្គលណាមួយទៀតឡើយ។

ព័ត៌មានដែលមានចរិតបុគ្គលឬផ្ទាល់ខ្លួនទាក់ទងនឹងអ្នកឆ្លើយ មិនត្រូវបានបញ្ចេញដោយរបៀបដែលអាចឱ្យសម្គាល់អត្តសញ្ញាណរបស់បុគ្គលនោះ។

ព័ត៌មានអំពីលេខនៃការចុះបញ្ជីអាជីវកម្ម ឈ្មោះ អាសយដ្ឋាន ទីតាំង ប្រភេទនៃការចាត់តាំងផ្លូវច្បាប់ផ្នែកផលិតកម្ម ចំនួនអ្នកធ្វើការ ឬកម្រិតថ្នាក់អថេរដទៃទៀត នៃអង្គភាពកសិកម្មនិងសហគ្រាស ហើយនិងអង្គភាពផ្សេងទៀត ដែលជាតម្រូវការរបស់វិទ្យាស្ថានជាតិស្ថិតិនិងអង្គភាពស្ថិតិដែលបានចាត់តាំង ដើម្បីបង្កើតក្របខ័ណ្ឌជំរឿននិងអង្កេត សម្រាប់គោលបំណងនៃការដឹកនាំសកម្មភាពប្រមូលទិន្នន័យនិងចងក្រងស្ថិតិផ្លូវការថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ មិនតម្រូវឱ្យមានការយល់ព្រមពីអ្នកឆ្លើយឡើយ។

**មាត្រា៣១ .-**

មន្ត្រីស្ថិតិនៃក្រសួងផែនការឬមន្ត្រីស្ថិតិដែលបានចាត់តាំង យោងតាមមាត្រា៣១និងមាត្រា៣២នៃច្បាប់ស្តីពីស្ថិតិ ត្រូវបង្ហាញលិខិតបញ្ជាបេសកកម្មរបស់ខ្លួន អត្តសញ្ញាណប័ណ្ណផ្លូវការ មានសិទ្ធិចេញចូលក្នុងទីកន្លែងដោយមានវត្តមានអ្នកកាន់កាប់ទីកន្លែង។ ទីកន្លែងស្នាក់នៅ រួមមាន ផ្ទះសំបែង ឬផ្នែកទីនៃបរិវេណផ្សេងទៀតដែលមានមនុស្សស្នាក់នៅដោយឡែក និងទីកន្លែងផ្សេងៗទៀតតាមពេលវេលាដ៏សមស្របសម្រាប់គោលដៅប្រមូលទិន្នន័យស្ថិតិ។

**មាត្រា៣២ .-**

បុគ្គលដែលទទួលកម្រងសំណួរឬទម្រង់ស្ថិតិដែលតម្រូវឱ្យបំពេញក្នុងរយៈពេលកំណត់ដូចមានចែងក្នុងមាត្រា២៧ចំណុចគឬមាត្រា២៨ចំណុចខនៃអនុក្រឹត្យនេះ ត្រូវមានកាតព្វកិច្ចបំពេញការងារនេះឱ្យបានសម្រេចជាស្ថាពរ។

## ជំពូកទី៧
## ទោសប្បញ្ញត្តិ

**មាត្រា៣៣ .-**

បុគ្គលណាដែលរំលោភបញ្ញត្តិនៃមាត្រា២៧ មាត្រា២៨ និងមាត្រា២៩នៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មវិន័យជាធរមាន។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា៣៤ .-**

រាល់លិខិតបទដ្ឋានគតិយុត្តទាំងឡាយណាដែលពាក់ព័ន្ធនឹងការតែងតាំងនិងការបង្កើតយន្តការនានាពាក់ព័ន្ធនឹងការរៀបចំនិងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា៣៥ .-**

អនុក្រឹត្យលេខ០៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ និងបទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ៣ កើត ខែ ភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

កិត្តិសេដ្ឋាបណ្ឌិត **ឆាយ ថន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ